ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសាកលវិទ្យាល័យបាត់ដំបង

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបាត់ដំបង

## ស ម្រេ ច

**មាត្រា ១..**

បង្កើតសាកលវិទ្យាល័យមួយ ស្ថិតនៅតាមផ្លូវជាតិលេខ ៥ ក្នុងឃុំព្រែកព្រះស្តេច ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដែលមានឈ្មោះថា **សាកលវិទ្យាល័យបាត់ដំបង** "University of Battambang" ហៅកាត់ជាភាសាខ្មែរ "ស.ប.ដ" និងហៅកាត់ជាភាសាអង់គ្លេស "U.B.B" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ២..**

សាកលវិទ្យាល័យបាត់ដំបង មានតួនាទីជាមជ្ឈមណ្ឌល បណ្តុះបណ្តាលធនធានមនុស្ស ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស និងលើកស្ទួយអត្តសញ្ញាណជាតិ ។

**មាត្រា ៣..**

ចំពោះមុខសាកលវិទ្យាល័យបាត់ដំបង ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ តាមកម្មវិធីសិក្សា ដែលមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤..**

សាកលវិទ្យាល័យបាត់ដំបង មានមហាវិទ្យាល័យប្រាំ និងវិទ្យាស្ថានមួយ :

-មហាវិទ្យាល័យសិល្បៈមនុស្សសាស្ត្រ និងអប់រំ
-មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
-មហាវិទ្យាល័យសង្គមសាស្ត្រ និងអភិវឌ្ឍសហគមន៍
-មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
-មហាវិទ្យាល័យកសិកម្ម និងកែច្នៃអាហារ និង
-វិទ្យាស្ថានភាសាបរទេស ។

ទៅអនាគត សាកលវិទ្យាល័យបាត់ដំបង អាចបើកមហាវិទ្យាល័យ ឯកទេស ក៏ដូច ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥..**

សាកលវិទ្យាល័យបាត់ដំបង មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និង សម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងការងារពាក់ព័ន្ធផ្សេងៗទៀត របស់សាកលវិទ្យាល័យ ។

**មាត្រា ៦..**

សាកលវិទ្យាល័យបាត់ដំបង ដឹកនាំដោយសាកលវិទ្យាធិការមួយរូប និងសាកលវិទ្យាធិការរងមួយរូប ឬច្រើនរូប ជាជំនួយការ ។

មាត្រា ៧.-

តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធគ្រប់គ្រង របស់សាកលវិទ្យាល័យបាត់ដំបង ត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៨.-

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំ មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ឱ្យបំរើការនៅក្នុងសាកលវិទ្យាល័យបាត់ដំបង ។

មាត្រា ៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ១៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្តបាត់ដំបង
- ដូចមាត្រា ៩ -រាជកិច្ច
- ឯកសារ -កាលប្បវត្តិ